# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 31-May-2013, 12:11
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សារណាបន្ថែមចំពោះបណ្តឹងសារទុក្ខតាមប្រឆាំងនឹងសេចក្តីសម្រេចលើកទី២របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី

---

<u>ដាក់ដោយ៖</u>

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

ព្រំ ផល្លា

សួន វិសាល

Joshua ROSESWEIG

Forest O'NEILL-GREENBERG

<u>**ផ្ញើជូន៖**</u>

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង**

**លោក Andrew CAYLEY**

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**PICH Ang**

**Elisabeth SIMONNEAU-FORT**

អនុលោមតាមវិធាន ១០៤(១), ១០៤(៤) និង១០៥(២) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“វិធានផ្ទៃក្នុង”) មេធាវីការពារក្តីជនជាប់ចោទ នួន ជា (“ក្រុមមេធាវីការពារក្តី”) តទៅនេះសូមដាក់សារណាបន្ថែមចំពោះបណ្តឹងសារទុក្ខភ្លាមរបស់ខ្លួន ប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនិតីវិធី (“បណ្តឹងសារទុក្ខ”)[1] ។

១. នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ មេធាវីការពារក្តីបានដាក់បណ្តឹងសារទុក្ខភ្លាមប្រឆាំងនឹងសេចក្តីសម្រេចចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ដោយបានបន្តជាថ្មីនូវការបំបែកកិច្ចដំណើរការនិតីវិធីនៅក្នុងសំណុំរឿង០០២។ ក្រុមមេធាវីការពារក្តី ក្នុងចំណោមបញ្ហាដទៃទៀត បានលើកអំណះអំណាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការសម្រេចឱ្យបន្តជាថ្មីនូវការបំបែកកិច្ចដំណើរការនិតីវិធី ហើយជាជម្រើសករណី០០២/០១ យ៉ាងហោចណាស់គួរតែដាក់បញ្ចូលការចោទប្រកាន់ដែលទាក់ទងនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងបទល្មើសនានាដែលកើតចេញពីសហករណ៍ និងការដ្ឋានធ្វើការ ។

២. ទាក់ទងនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មេធាវីការពារក្តីលើកអំណះអំណាង (មួយផ្នែក) ដូចខាងក្រោម៖

> នួន ជា ត្រូវតែបានផ្តល់ឱកាស ដើម្បីជំទាស់រាល់ការចោទប្រកាន់ទាំងអស់ប្រឆាំងនឹងរូបគាត់។ ដូចដែលមេធាវីការពារក្តីបានលើកអំណះអំណាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថា ដីកាដំណោះស្រាយ គឺជាការចោទប្រកាន់តាមផ្លូវតុលាការដែលត្រូវបានចាត់ទុកថា នួន ជា “ប្រហែលជា” មានទោសកំហុសពីបទឧក្រិដ្ឋអន្តរជាតិធ្ងន់ធ្ងរ។ ផ្នែកណាមួយនៃដីកាដំណោះស្រាយដែលមិនត្រូវបានយកមកពិភាក្សាដេញដោលនៅសវនាការ “នឹងត្រូវប្រើប្រាស់សម្រាប់ការវិនិច្ឆ័យទោសចុងក្រោយលើការទទួល

---

[1] ឯកសារ **E-284/4/1**, “បណ្តឹងសារទុក្ខភ្លាមប្រឆាំងនឹងសេចក្តីសម្រេចលើកទី២របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនិតីវិធី និងចម្លើយតបទៅនឹងបណ្តឹងសារទុក្ខភ្លាមរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចលើកទី២ របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការ” ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ (“បណ្តឹងសារទុក្ខ”)។

ខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា លើអង្គហេតុនានាក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ។ នួន ជា ស្ទើរតែមិនត្រូវផ្តល់សិទ្ធិអ្វីទាំងអស់ក្នុងការចូលរួមកិច្ចស៊ើបសួរឡើយ។ អាស្រ័យហេតុនេះការជំនុំជម្រះដែលកំពុងតែបន្តនេះ “គឺជាឱកាសតែមួយគត់របស់គាត់ ដើម្បីបង្ហាញការការពារខ្លួនរបស់គាត់ទៅលើការចោទប្រកាន់នានានៅក្នុងដីកាដំណោះស្រាយ” និងសម្រាប់ឲ្យប្រជាជនកម្ពុជាស្តាប់ឮការពិតបំផុតនៃប្រវត្តិសាស្ត្រ។

...

ដីកាដំណោះស្រាយចោទប្រកាន់ នួន ជា ពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយបាន “កំណត់អត្តសញ្ញាណ កំណត់ជនគោលដៅ ប្រមូល និងសម្លាប់ដោយចេតនា និងជាប្រព័ន្ធ” មកលើប្រជាជនរាប់ពាន់នាក់ ដោយសារតែពួកគេជាសមាជិកនៃក្រុមជាតិសាសន៍មួយឬក្រុមសាសនាមួយ។ ដីកាដំណោះស្រាយសន្និដ្ឋានថា នួន ជា មានចេតនាជាក់លាក់ដើម្បីបំផ្លាញក្រុមទាំងនោះ និងបានស្វែងរកការបំផ្លាញពួកគេទាំងស្រុង។ ការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ គឺជាការកំណត់ខុសដ៏អាក្រក់បំផុតចំពោះខ្មែរក្រហម ឬតួនាទីរបស់ នួន ជា ថា ជាមេដឹកនាំម្នាក់របស់ខ្មែរក្រហមនោះ។

ភាពធ្ងន់ធ្ងរនៃការចោទប្រកាន់ប្រល័យពូជសាសន៍ តម្រូវឲ្យអង្គជំនុំជម្រះនេះត្រូវតែប្រុងប្រយ័ត្ននៅក្នុងការធានាថា សិទ្ធិរបស់ នួន ជា ដើម្បីជំទាស់នឹងការចោទប្រកាន់ប្រឆាំងនឹងរូបគាត់ ត្រូវបានគោរព។ ដីកាដំណោះស្រាយសន្និដ្ឋានថា នួន ជា “ប្រហែល” ជាបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលអាក្រក់បំផុតដែលមនុស្សលោកស្គាល់។ តុលាការនេះមិនអាចគ្រាន់តែសម្រេចថា បទចោទនេះមិនសំខាន់គ្រប់គ្រាន់ដើម្បីយកមកជំនុំជម្រះឡើយ។ តុលាការនេះមិនអាចបន្សល់ទុកដោយចេតនានូវ*សេចក្តីសម្រេច*ប្រឆាំងនឹង នួន ជា ថាគាត់ប្រហែលជាមានចេតនាបំផ្លាញទាំងស្រុងនៃក្រុមមនុស្ស ។

សំខាន់ដូចនេះដែរ គឺតួនាទីពិសេសដែលត្រួតត្រាដោយប្រយោគ “ប្រល័យពូជសាសន៍” ដែលហ៊ុំព័ទ្ធជុំវិញរយៈកាលកម្ពុជាប្រជាធិបតេយ្យនៅក្នុងផ្នត់គំនិតរបស់ប្រជាជន។ ស្ថាប័នដែលបង្កើតមជ្ឈមណ្ឌល DC-CAM ដែលបានប្រមូលភស្តុតាង

សឹងតែទាំងអស់សម្រាប់ការជំនុំជម្រះនេះ គឺកម្មវិធីប្រល័យពូជសាសន៍កម្ពុជារបស់សកលវិទ្យាល័យ Yale (Yale University's 'Cambodian Genocide Program') ប្រដូចកម្ពុជាប្រជាធិបតេយ្យ ទៅនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទាំងអស់នៅសតវត្សទី២០៖

> ប្រល័យពូជសាសន៍នៅកម្ពុជាពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលបានសម្លាប់ជីវិតមនុស្សប្រមាណ១,៧លាននាក់ (ស្មើនឹង២១%នៃប្រជាជនរបស់ប្រទេស) គឺជាសោកនាដកម្មមនុស្សលោកដ៏អាក្រក់បំផុតនៃសតវត្សរ៍កន្លងមក។ ដូចគ្នានឹងអាណាចក្រ Ottoman ក្នុងអំឡុងពេលប្រល័យពូជសាសន៍លើប្រជាជនអាមេនី (Armenia) ណាស៊ីអាល្លឺម៉ង់ ហើយនាពេលថ្មីៗនេះនៅកោះទីម័រខាងកើត ប្រទេសGuatemala, យូហ្គោស្លាវី និងរ៉្វាន់ដា របបខ្មែរក្រហមដែលដឹកនាំដោយ ប៉ុល ពត រួមជាមួយមនោគមន៍វិជ្ជាផ្តាច់ការហួសហេតុជាមួយនឹងកំហឹងជាតិពន្ធុ និងការមិនគោរពជីវិតមនុស្ស ដើម្បីបង្កើតការគាបសង្កត់ ទុក្ខភាព និងការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ។

ថ្វីត្បិតសាធារណជនយល់ឃើញបែបនេះ ក៏អំពើប្រល័យពូជសាសន៍ គឺជាបទល្មើសមួយក្នុងចំណោមអំពើល្មើសតិចតួចដែលបានកើតឡើង ត្រូវបានជំទាស់ដោយអ្នកជំនាញដែលចាត់តាំងដោយរដ្ឋអាជ្ញាដែរ។ លើសពីការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ មតិយោបល់សាធារណជនអំពីតួនាទីរបស់ប្រល័យពូជសាសន៍នៅក្នុងរបបខ្មែរក្រហម នាំឲ្យយល់ខុសលើកំណត់ត្រាប្រវត្តិសាស្ត្រ។ តុលាការនេះនិងការប្រកាសជាធារណៈរបស់ខ្លួននៃការចោទប្រកាន់ប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាប់ចោទ នឹងត្រូវស្តីបន្ទោសពីការបង្កើតទស្សនទាននេះ។ នួន ជា ត្រូវតែបានផ្តល់ឱកាសដើម្បីជំទាស់នឹងការចោទប្រកាន់នេះ កែតម្រូវកំណត់ត្រាសាធារណៈ និងបង្ហាញថា គាត់មិនបានសម្លាប់ប្រជាជនរបស់គាត់ទេ[2]។

---

[2] បណ្តឹងសារទុក្ខ នៅកថាខណ្ឌ៣៣, ៣៨-៤១។

៣. ស្របពេលដែលក្រុមមេធាវីការពារ នួន ជា ហៀបនឹងបញ្ចប់ទឡ្ហីករណ៍នេះនៅក្នុងបណ្តឹងសារទុក្ខនេះលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កំពុងតែពន្យល់លើចំណុចពិតនេះនៅវត្តលង្កា។ ឆ្លើយតបទៅនឹងការអធិប្បាយរបស់លោក កឹម សុខា ប្រធានស្តីទីគណបក្សសង្គ្រោះជាតិកម្ពុជា (CNRP) លោក ហ៊ុន សែន ថ្លែងថា៖

> ពិភាក្សាជាមួយសមាជិករដ្ឋសភាមកពីគណបក្សប្រជាជន ដើម្បីពង្រាងជាបន្ទាន់នូវសេចក្តីព្រាងច្បាប់សម្រាប់រដ្ឋសភាដាក់ទោសជនណាដែលនិយាយថា ខ្មែរក្រហមមិនសម្លាប់ប្រជាជន និងនិយាយថាពុំមានកន្លែងធ្វើទារុណកម្មដូចទួលស្លែង[...]ទេនោះ។ យើងគួរធ្វើច្បាប់ដូចនៅអឺរ៉ុប ដើម្បីដាក់ទោសជនណាដែលនិយាយថា ពុំមានរបបប្រល័យពូជសាសន៍ខ្មែរក្រហម[3]។

ដោយមិនឱ្យចាញ់ប្រៀប CNRP ឆ្លើយតបទៅនឹងការអធិប្បាយរបស់លោកនាយករដ្ឋមន្ត្រី ដោយបានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការថ្កោលទោស "របបប្រល័យពូជសាសន៍ខ្មែរក្រហម"[4]។

---

[3] Neou Vannarin and Zsombor Peter, "ហ៊ុន សែន ស្នើឱ្យធ្វើច្បាប់ប្រឆាំងនឹងអ្នកដែលបដិសេធពីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម" កាសែត Cambodia Daily, ចុះផ្សាយថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ (អត្ថបទសារព័ត៌មានរបស់ Cambodia Daily អាចរកបាននៅ: http://www.cambodiadaily.com/news/hun-sen-calls-for-law-against-denial-of-kr-crimes-27128/ ។ ស្រដៀងគ្នានេះ ការថ្លែងរបស់លោកនាយករដ្ឋមន្ត្រី មានចុះផ្សាយនៅលើទំព័រសារព័ត៌មានភាសាខ្មែរ និងនៅសារព័ត៌មានអន្តរជាតិ។ ឧទាហរណ៍ កាសែតកោះសន្តិភាព ចុះផ្សាយថ្ងៃទី២៧ ខែឧសភា ដែលអាចរកបាននៅ http://kohsantepheapdaily.com.kh/article/71990.html, សារព័ត៌មានដើមអំពិលនៅ: http://www.dap-news.com/2011-06-14-02-39-55/64906-2013_05-29-00-26-57 "បានភ្ជាប់បក្សប្រឆាំងជាមួយខ្មែរក្រហម, នាយកកម្ពុជាស្វែងរកច្បាប់ដើម្បីដាក់ទណ្ឌកម្មអ្នកដែលបដិសេធអំពីឃោឃៅ" (Associated Press) ចុះផ្សាយថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ អាចរកបាន online នៅ: http://www.washingtonpost.com/world/asia_pacific/linking-opponents-to-khmer-rouge-cambodia-pm-seeks-law-to-punish-those-who-deny-atrocities/2013/05/27/786139f0-c6e7-11e2-9cd9-3b9a22a4000a_story.html ។ សម្រង់នៅទីនេះយកចេញពីអត្ថបទរបស់កាសែត Cambodia Daily ។

[4] អត្ថបទរបស់កាសែត Cambodia Daily ។

៤. ការអំពាវនាវរបស់លោក ហ៊ុន សែន ឱ្យមានច្បាប់ដើម្បីដាក់ទណ្ឌកម្មចំពោះការបដិសេធ "ប្រល័យពូជសាសន៍" របស់ខ្មែរក្រហម បន្ថែមលើភាពបន្ទាន់រឹងមាំទៅលើការស្វះស្វែងរបស់ក្រុមមេធាវីការពារក្តី ឱ្យវិនិច្ឆ័យលើបទចោទប្រល័យពូជសាសន៍នៅតុលាការនេះ។ ដូចដែលមេធាវីការពារក្តីបានលើកអំណេះអំណាងនៅក្នុងបណ្តឹងសារទុក្ខរបស់ខ្លួន ការជឿជាទូទៅថាខ្មែរក្រហមបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ គឺគ្រាន់តែជាការក្លែងក្លាយ។ ពេលនេះលោក ហ៊ុន សែន ស្នើឱ្យតម្កល់ការក្លែងក្លាយថាជាការសន្មតជាមុនដែលមិនអាចជំទាស់បាននៅក្នុងច្បាប់កម្ពុជា ។

៥. ការអំពាវនាវរបស់លោក ហ៊ុន សែន ឱ្យដាក់ទោសចំពោះការបដិសេធមិនទទួលស្គាល់ "ប្រល័យពូជសាសន៍នៅកម្ពុជា គឺជារឿងរ៉ាវចុងក្រោយបំផុតនៅក្នុងកិច្ចប្រឹងប្រែងអស់មួយទសវត្សដោយរដ្ឋាភិបាលបច្ចុប្បន្ន និងបុព្វការីជនរបស់ខ្លួន ដើម្បីដាក់ប្រល័យពូជសាសន៍នៅជុំវិញករបស់ នួន ជា និងមេដឹកនាំដទៃទៀតនៃបក្សកុម្មុយនីស្តកម្ពុជា។ កិច្ចប្រឹងប្រែងនោះចាប់ផ្តើមជាមួយនឹងការជំនុំជម្រះបទប្រល័យពូជសាសន៍ប្រឆាំងនឹង ប៉ុល ពត និង អៀង សារី នៅតុលាការបដិវត្តប្រជាជន និងការបង្កើតអ្វីមួយដែលហៅថា "សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង" ។ ការវិនិច្ឆ័យទោសនៅតុលាការនេះប្រឆាំងនឹង នួន ជា ចំពោះឧក្រិដ្ឋកម្មដែលត្រូវគេប្រព្រឹត្តនៅមន្ទីរ ស-២១ តែប៉ុណ្ណឹង នឹងធ្វើឱ្យការភ័នច្រឡំកាន់រឹងមាំថែមទៀត។ ការវិនិច្ឆ័យពេញលេញ និងដោយយុត្តិធម៌លើបទចោទប្រល័យពូជសាសន៍ នឹងត្រូវប្រើពេលវេលាដែលឈានទៅរកការកែតម្រូវវា ។

៦. សិទ្ធិរបស់ នួន ជា ក្នុងការឆ្លើយតបទៅនឹងការចោទប្រកាន់ប្រឆាំងនឹងរូបគាត់នៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿងដែលមានកម្រាស់៨០០ទំព័រ តម្រូវឱ្យអង្គជំនុំជម្រះតុលាការកំពូលចាប់យកគន្លងផ្លូវទីពីរ។ ដូចដែលមេធាវីការពារក្តីបានបង្ហាញនៅក្នុងបណ្តឹងសារទុក្ខភ្លាម- ព្រឹត្តិការណ៍នៅសប្តាហ៍នេះបញ្ជាក់ជាថ្មីម្តងទៀត-ប្រល័យពូជសាសន៍បានហ៊ុំព័ទ្ធរួចមកហើយនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យនៅក្នុងផ្នត់គំនិតសាធារណជន។ សាធារណជនហាក់ដូចជាប្រញាប់ប្រញាល់គាំទ្រការយល់ឃើញបែបនេះ។ ច្បាប់ដែលស្នើឡើងដោយលោក ហ៊ុន សែន ពេលនេះនឹងបញ្ចប់ការខ្វែងយោបល់ស្របច្បាប់គ្រប់ពេលវេលាទាំងអស់។ ការជំនុំ

ជម្រះបទប្រល័យពូជសាសន៍នៅតុលាការនេះ គឺរឿងត្រឹមត្រូវបំផុត ហើយវាអាចជាឱកាសចុងក្រោយ ដើម្បីធ្វើការពិភាក្សាជាសាធារណៈ និងបើកចំហលើបញ្ហាដ៏សំខាន់ចំពោះ នួន ជា និងប្រជាជនកម្ពុជាផងដែរ ។

៧. អាស្រ័យដូចបានបញ្ជាក់ក្នុងមូលហេតុខាងលើ មេធាវីការពារក្ដីស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលៈ

ក. ទទួលសារណាបន្ថែមនេះ និង

ខ. ពិចារណាសារណាបន្ថែមនេះជាមួយគ្នានឹងបណ្ដឹងសារទុក្ខភ្លាមក្នុងការគាំទ្រដល់សំណើរបស់មេធាវីការពារក្ដី សុំឱ្យអង្គជំនុំជម្រះនេះដាក់បញ្ចូលបទចោទប្រល័យពូជសាសន៍ ជាផ្នែកនៃវិសាលភាពនៃសំណុំរឿង០០២/០១ ។

**សហមេធាវីការពារក្ដីលោក នួន ជា**

**សុន អរុណ** Victor KOPPE